វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៤៣សជណ.កបច/ *ថ្ងៃទី ០៦ ខែកញ្ញាឆ្នាំ២០០១*

**សេចក្តីជូនដំណឹង ស្តីពីការបញ្ចប់ការចូលកាន់កាប់ភោគៈលើអចលនវត្ថុ**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ ព្រមទាំងប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា ច្បាប់ភូមិបាល ដែលរដ្ឋសភា និងព្រឹទ្ធសភា ទើបបានអនុម័ត កាលពីខែកក្កដា និងសីហា ឆ្នាំ ២០០១ កន្លងទៅនេះ ត្រូវបានព្រះករុណាជាម្ចាស់ជីវិតលើត្បូងឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ នាថ្ងៃ ទី៣០ ខែ សីហា ឆ្នាំ ២០០១ រួចហើយ ។ ដោយបទប្បញ្ញត្តិ នៃមាត្រា ២៩ វាក្យខ័ណ្ឌទី ២ នៃច្បាប់នេះ បានចែងច្បាស់ថា " ការចូលកាន់កាប់ភោគៈ ត្រូវបញ្ចប់នៅពេលដែលច្បាប់នេះចូលជាធរមាន" រាជរដ្ឋាភិបាល សូមប្រកាសថា អំនើរទៅ រាល់ការកាន់កាប់ភោគៈលើ អចលនវត្ថុ ត្រូវហាមឃាត់ ។

ដើម្បីធានាឱ្យការអនុវត្តច្បាប់ភូមិបាលនេះមានសិទ្ធភាពខ្ពស់ ក៏ដូចជាការរក្សាសណ្តាប់ធ្នាប់សាធារណៈឱ្យបានរៀបរយល្អប្រសើរ រាជរដ្ឋាភិបាល សូមកំណត់តំនូវវិធានការដូចខាងក្រោម :

- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចាត់វិធានការទប់ស្កាត់ និងហាមឃាត់ មិនឱ្យមានការចូលកាន់កាប់ដីថ្មី លើអចនលវត្ថុ និងការរានដីថ្មី
- គ្រប់ក្រសួង ស្ថាប័ន ត្រូវចូលរួមសហការ និងបង្កលក្ខណៈដល់អាជ្ញាធរខេត្ត ក្រុង ដើម្បីអនុវត្តវិធានការបញ្ចប់ការចូលកាន់កាប់ភោគៈនេះឱ្យមានប្រសទ្ធិភាពខ្ពស់ ។

ចំពោះភោគស្របច្បាប់ ដែលមានកន្លងមកមុនច្បាប់នេះចូលជាធរមាន ដោយយោងតាមមាត្រា ៤០ នៃ ច្បាប់ភូមិបាលថ្មី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបន្តចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចនវត្ថុ ជូនប្រជាពលរដ្ឋបន្តទៀត ដោយធ្វើការកែសម្រួលនីតិវិធីនៃការផ្តល់ប័ណ្ណ ស្របតាមខ្លឹមសារនៃច្បាប់ភូមិបាលនេះ ។